ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
គណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជា
ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ
លេខៈ......០០៦/......គ.ផ.ថ/ស.ជ.ណ
១៦

# សេចក្ដីជូនដំណឹង
## ស្ដីពី នីតិវិធីនៃការទទួលបានភាពស្របច្បាប់របស់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការ នៅប្រទេសថៃចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០១៦

គណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជូនដំណឹងដល់សាធារណៈជន ជាពិសេសពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបថាៈ

១. គណៈកម្មការមិនដែលតម្រូវឱ្យពលករណាម្នាក់បង់សេវាបន្ថែមក្រៅពីសេវាដែលមានគោលការណ៍ និងបិទផ្សាយជាសាធារណៈនៅតាមច្រកចេញចូលតែមួយរបស់ភាគីថៃនោះឡើយ។ ក្នុងករណីដែលមានជនណាមួយអះអាងថាជាមន្ត្រីស្ថានឯកអគ្គរាជទូតឬមន្ត្រីនៃគណៈកម្មការ ហើយស្នើសុំថវិកាបន្ថែមនោះសូមបងប្អូនពលករមេត្តាប្ដឹងអាជ្ញាធរមានសមត្ថកិច្ចថៃ ឬជូនដំណឹងមកស្ថានឯកអគ្គរាជទូតកម្ពុជាតាមរយៈទូរស័ព្ទលេខ ០៩៨៤០៤១៥៥០ ឬ ០៨៦៧៩៩៩៩៥៧ ឬ០៩៤០៩២៥៩០៥។

២. យោងសំណើរបស់ក្រសួងការងារថៃ គណៈកម្មការបានផ្អាកការចុះស្រង់ទិន្នន័យពលករ និងបើកផ្ដល់លិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ដើម្បីទុកលទ្ធភាពឱ្យភាគីថៃធ្វើដំរឿន និងបន្តប័ណ្ណស៊ីជំពូឡើងវិញ។

៣.ដើម្បីផ្ដល់ភាពងាយស្រួល និងបង្កើនល្បឿនក្នុងការទទួលបានភាពស្របច្បាប់ ភាគីថៃបានទទួលយកសំណើពីភាគីកម្ពុជាដោយៈ

- ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ គណៈកម្មការផ្ដល់ភាពស្របច្បាប់ នឹងចាប់ផ្ដើមទទួលពាក្យស្នើសុំដកលិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេសពីបងប្អូនពលករឡើងវិញតាមច្រកចេញចូលតែមួយ (One Stop Service) ឬមន្ទីរការងារថៃទាំង៧៧កន្លែង។
- ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ គណៈកម្មការផ្ដល់ភាពស្របច្បាប់ នឹងចាប់ផ្ដើមបើកផ្ដល់លិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេសដល់បងប្អូនពលករដើម្បីយកទៅបន្តនីតិវិធីទទួលបានភាពស្របច្បាប់នៅតាមច្រកចេញចូលតែមួយ (One Stop Service) ឬមន្ទីរការងារថៃទាំង៧៧កន្លែង។
- ពលករកម្ពុជាដែលបានផ្លាស់ប្ដូរនិយោជកក៏អាចសុំភាពស្របច្បាប់ឡើងវិញបានដែរ។

៤.មានតែកម្រៃសេវាដែលនឹងបិទផ្សាយនៅតាមច្រកចេញចូលតែមួយ (One Stop Service) ឬមន្ទីរការងារថៃទាំង៧៧កន្លែង ចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០១៦ ប៉ុណ្ណោះដែលជាកម្រៃសេវាផ្លូវការដែលមានការឯកភាពដោយភាគីថៃ និងកម្ពុជា។

គណៈកម្មការសូមជម្រាបថា កន្លងមកពលករកម្ពុជាអាចស្នើសុំដកលិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស ដើម្បីស្នើសុំភាពស្របច្បាប់ពីអាជ្ញាធរថៃនៅច្រកចេញចូលតែមួយក្នុងខេត្តសាមុតប្រាកានតែមួយប៉ុណ្ណោះ។

អាស្រ័យន័យដូចបានជម្រាបជូនខាងលើ សូមសាធារណៈជន ជាពិសេសពលករដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញថ្ងៃទី ២០ ខែមេសា ឆ្នាំ២០១៦
**រដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការ**

**អ៊ិត សំហេង**